ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រធានគណៈមេធាវី**

មេធាវី លី ច័ន្ទតុលា

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ខូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ឈាប គុណាថុល
២០-មេធាវី យ៉ឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្រ្ត
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា

លេខ ១១៦ /សសគម/២១

# សេចក្តីសម្រេច

## ស្តីពី

## នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

## ស ម្រេ ច

ដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖



អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងបង្កើននូវប្រសិទ្ធភាព តម្លាភាព ជំនឿទុកចិត្តលើការធ្វើអធិការកិច្ច និងការធ្វើសេចក្តីសម្រេចជ្រើសរើសបេក្ខជនសុំចូលប្រកបវិជ្ជាជីវៈមេធាវី ប្រកបដោយគុណភាព និងសមត្ថភាព ព្រមទាំងការត្រួតពិនិត្យលើការធ្វើកម្មសិក្សា តាមរយៈការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី និងការត្រួតពិនិត្យលើការធ្វើកម្មសិក្សារបស់មេធាវីជាកម្មសិក្សាការី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

### ប្រការ២ .. វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះបេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី តាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មេធាវីជាគ្រូកម្មសិក្សា និងមេធាវីជាកម្មសិក្សាការី ។

## ជំពូកទី២
## លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

## ផ្នែកទី១
## លក្ខខណ្ឌ និងការដាក់ពាក្យសុំ

### ប្រការ៣ .. លក្ខខណ្ឌ

ជនដែលមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរ ។

២- ត្រូវមានបរិញ្ញាបត្រច្បាប់ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល ។

៣- ត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលចេញដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៥- មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

### ប្រការ៤ .. ទម្រង់នៃពាក្យសុំ

ជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបានកំណត់ក្នុងប្រការខាងលើ ហើយមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវមកទិញពាក្យសុំចូលប្រកបវិជាជីវៈមេធាវីនៅនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការប្រកាសរបស់គណៈមេធាវីនៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ។

តម្លៃនៃពាក្យសុំត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

### ប្រការ៥ .. ការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី នៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

២-ប្រវត្តិរូបសង្ខេបសាមីខ្លួន

៣-កិច្ចសន្យាផ្ទាល់ខ្លួន

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៥-រូបថត ៤ គុណ ៦ ចំនួន៤ (បួន)សន្លឹក

៦-វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ចំនួន២ (ពីរ)ច្បាប់ ដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

៧-លិខិតថ្កោលទោសដែលនៅមានសុពលភាព

៨-ឯកសារតម្រូវផ្សេងៗ ដែលកំណត់ដោយគណៈមេធាវី ។

## ផ្នែកទី២
## នីតិវិធីនៃការធ្វើសេចក្តីសម្រេច និងការប្តឹងតវ៉ា

### ប្រការ៦ .. ការស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា

ក្រោយពីពិនិត្យឃើញថាពាក្យសុំត្រូវបានបំពេញគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការខាងលើរួចរាល់ គណៈមេធាវីត្រូវបញ្ជូនសំណុំឯកសាររបស់បេក្ខជនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីត្រួតពិនិត្យលើលក្ខខណ្ឌដែលកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា ។ សំណុំឯកសារដែលត្រូវបញ្ជូនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល រួមមានពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ប្រវត្តិរូបសង្ខេប កិច្ចសន្យាផ្ទាល់ខ្លួន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងលិខិតថ្កោលទោស ។

### ប្រការ៧ .. ការពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី

ការយល់ព្រមឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ការបោះឆ្នោតដើម្បីអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវធ្វើជាសម្ងាត់ ។ ការសម្រេចគាំទ្របេក្ខជនត្រូវធ្វើឡើងតាមសំឡេងភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាននិងសំឡេងផ្ទេរសិទ្ធិ ដោយធៀបទៅនឹងលទ្ធផលសំឡេងយល់ព្រម មិនយល់ព្រម អនុប្បវាទឬមិនបានការ ។

ករណីសំឡេងអនុប្បវាទឬមិនបានការ ច្រើនជាងឬស្មើនឹងសំឡេងយល់ព្រមឬ/និងមិនយល់ព្រម ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី ។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ ។

ក្នុងករណីសំឡេងយល់ព្រមនិងមិនយល់ព្រមស្មើគ្នា ហើយច្រើនជាងសំឡេងអនុប្បវាទឬមិនបានការ ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ។

ក្នុងករណីដែលក្រុមប្រឹក្សាគណៈមេធាវី សម្រេចមិនអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវៈមេធាវី ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញបេក្ខជនរូបនោះមកបញ្ចេញយោបល់នៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី។ ការកោះអញ្ជើញនេះត្រូវធ្វើឡើងយ៉ាងតិច១០(ដប់)ថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី។ បន្ទាប់ពីស្តាប់យោបល់របស់សាមីខ្លួនរួចហើយ សមាជិកក្រុមប្រឹក្សាគណៈមេធាវីអាចតាំងសំណួរបន្ថែមបាន។ ក្រោយការសួរសំណួរចប់សព្វគ្រប់ សាមីខ្លួនត្រូវចាកចេញពីបន្ទប់ប្រជុំ ហើយក្រុមប្រឹក្សាគណៈមេធាវីត្រូវពិភាក្សាគ្នានិងធ្វើការសម្រេចជាថ្មី។

## ប្រការ៨ .. ការប្តឹងតវ៉ាពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី

ក្នុងករណីក្រុមប្រឹក្សាគណៈមេធាវីសម្រេចមិនអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី គណៈមេធាវីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅសាមីខ្លួន ហើយសាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងរយៈពេល២(ពីរ)ខែចាប់ពីថ្ងៃទទួលដំណឹង។

## ប្រការ៩ .. ការពិនិត្យនិងសម្រេចឡើងវិញ

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យលើសេចក្តីសម្រេចរបស់ខ្លួននិងសម្រេចឡើងវិញ តាមសាលដីការបស់តុលាការ។

# ជំពូកទី៣
# លក្ខខណ្ឌនិងនីតិវិធីនៃការពិនិត្យនិងសម្រេចឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

## ផ្នែកទី១
## លក្ខខណ្ឌសម្រាប់បេក្ខជន

### ប្រការ១០ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលជាចៅក្រមនិងអតីតចៅក្រម

បេក្ខជនជាចៅក្រមដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី៥(ប្រាំ)ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ ហើយដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី២(ពីរ)ឆ្នាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

### ប្រការ១១ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ

បេក្ខជនជាមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៤-ត្រូវមានការបញ្ជាក់អំពីការចុះបញ្ជីពីគណៈមេធាវីនៃប្រទេសណាមួយដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ។

## ប្រការ១២ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលមានសញ្ញាបត្របណ្ឌិតច្បាប់

បេក្ខជនដែលមានសញ្ញាបត្របណ្ឌិតច្បាប់ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៤-ក្នុងករណីសញ្ញាបត្របណ្ឌិតចេញដោយប្រទេសក្រៅ បេក្ខជនត្រូវមានលិខិតបញ្ជាក់ពីក្រសួងទទួលបន្ទុកវិស័យអប់រំថាមានតម្លៃសមមូលជាមួយសញ្ញាបត្របណ្ឌិតច្បាប់ ។

## ប្រការ១៣ .. លក្ខខណ្ឌសម្រាប់បេក្ខជនដែលបានបម្រើការងារក្នុងវិស័យច្បាប់ឬតុលាការ

បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រច្បាប់ ហើយដែលបានបម្រើការងារក្នុងវិស័យច្បាប់ឬតុលាការលើសពី២(ពីរ)ឆ្នាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ ។

២-មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬបទវិន័យ ឬបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។

៣-មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

ការងារក្នុងវិស័យច្បាប់ គឺជាការងារដែលបុគ្គលនោះបានបំពេញទាក់ទងនឹងច្បាប់ទាំងក្នុងស្ថាប័នសាធារណៈ ឬឯកជន ដូចជាៈ ការពិគ្រោះច្បាប់ ការតាក់តែងលិខិតស្នាមគតិយុត្ត ការផ្សះផ្សាការសម្របសម្រួលដែលមានវិជ្ជាជីវៈទទួលស្គាល់ដោយច្បាប់ មជ្ឈត្តករ ការបង្រៀនមុខវិជ្ជាច្បាប់ ការស្រាវជ្រាវច្បាប់ និងការងារទាក់ទងវិជ្ជាជីវៈមេធាវី ។

# ផ្នែកទី២
# ការដាក់ពាក្យសុំ

## ប្រការ១៤ .. ទម្រង់នៃពាក្យសុំ

បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបានកំណត់ក្នុងប្រការខាងលើ ហើយមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវមកទិញពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី នៅនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមការប្រកាសរបស់គណៈមេធាវីនៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ។

តម្លៃនៃពាក្យសុំនិងថ្លៃដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

## ប្រការ១៥ .. ការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី នៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

២-ប្រវត្តិរូបសង្ខេបសាមីខ្លួន

៣-កិច្ចសន្យាផ្ទាល់ខ្លួន

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៤-រូបថត ៤ គុណ ៦ ចំនួន៤សន្លឹក

៥-បរិញ្ញាបត្រច្បាប់ឬសញ្ញាប័ត្រសមមូល(ច្បាប់ដើម) ឬសញ្ញាបត្រមធ្យមសិក្សាច្បាប់(ច្បាប់ដើម) ឬព្រះរាជក្រឹត្យតែងតាំងជាចៅក្រម ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១០ និងប្រការ១៣

៦-សញ្ញាបត្របណ្ឌិតច្បាប់(ច្បាប់ដើម) ឬលិខិតបញ្ជាក់ពីក្រសួងទទួលបន្ទុកវិស័យអប់រំថាមានតម្លៃសមមូលជាមួយសញ្ញាបត្របណ្ឌិតច្បាប់ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១២

៧-ត្រូវមានការបញ្ជាក់អំពីការចុះបញ្ជីពីគណៈមេធាវីនៃប្រទេសណាមួយ ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១១

៨-លិខិតថ្កោលទោសដែលនៅមានសុពលភាព

៩-លិខិតបញ្ជាក់ការងារ ករណីបេក្ខជនដាក់ពាក្យស្នើសុំស្របតាមប្រការ១៣

១០-ឯកសារតម្រូវផ្សេងៗ ដែលកំណត់ដោយគណៈមេធាវី ។

## ប្រការ១៦ .. ការទទួលខុសត្រូវរបស់បេក្ខជន

បេក្ខជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ឯកសារទាំងឡាយដែលមាននៅក្នុងពាក្យសុំរបស់ខ្លួន។

## ប្រការ១៧.. ការទទួល និងបញ្ជូនឯកសារពាក្យសុំ

នៅពេលទទួលពាក្យសុំ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលគណៈមេធាវីត្រូវពិនិត្យមើលឯកសារជាមូលដ្ឋានដែលបានកំណត់នៅក្នុងពាក្យសុំ ។ ប្រសិនបើពិនិត្យឃើញថាពាក្យសុំមិនមានឯកសារឬមិនបានបំពេញគ្រប់លក្ខខណ្ឌទេ នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលត្រូវជូនដំណឹងដល់បេក្ខជនឬបេក្ខនារីអោយបំពេញបន្ថែមអំពីការខ្វះខាតនោះ និងតម្រូវឱ្យបេក្ខជនបង់ប្រាក់ថ្លៃដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ។

## ផ្នែកទី៣
## ការធ្វើអធិការកិច្ច

### ប្រការ១៨ .. ការចាត់តាំងអធិការកិច្ច

ក្រោយពេលទទួលពាក្យសុំរបស់បេក្ខជន ប្រធានគណៈមេធាវីចាត់តាំងក្រុមអធិការកិច្ចតាមសំណើរបស់ប្រធាននាយកដ្ឋានអធិការកិច្ច ដើម្បីត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ និងធ្វើការសម្ភាសន៍បុគ្គលដែលពាក់ព័ន្ធដើម្បីពិនិត្យភាពត្រឹមត្រូវនៃព័ត៌មានដែលអះអាងដោយបេក្ខជន។

ក្នុងករណីបេក្ខជនជាមេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីក្រៅប្រទេស ក្រុមអធិការកិច្ចត្រូវស្រាវជ្រាវរកភាពត្រឹមត្រូវនៃការបញ្ជាក់របស់គណៈមេធាវីនោះ តាមគ្រប់មធ្យោបាយ ហើយការចំណាយជាក់ស្តែងចាំបាច់ណាមួយ ជាបន្ទុករបស់បេក្ខជន។

### ប្រការ១៩ .. សមាសភាពអធិការកិច្ច

ក្រុមអធិការកិច្ចដែលទទួលបន្ទុកពិនិត្យលើពាក្យសុំរបស់បេក្ខជនត្រូវមានសមាសភាពចំនួន០២(ពីរ)នាក់ ដោយមានម្នាក់ជាប្រធានក្រុមនិងម្នាក់ទៀតជាសមាជិក ត្រូវបំពេញការងារនិងទទួលខុសត្រូវរួមគ្នាលើលទ្ធផលនៃការធ្វើអធិការកិច្ច ដោយត្រូវរាយការណ៍អំពីលទ្ធផល ឧបសគ្គ ឬបញ្ហាដែលអាចកើតមានជាយថាហេតុជូនប្រធានគណៈមេធាវី។

ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ មានសីលធម៌ និងស្មោះត្រង់។ សមាសភាពក្រុមអធិការកិច្ចដែលត្រូវបានចាត់តាំង ប្រសិនបើក្នុងចំណោមនោះមានទំនាក់ទំនងញាតិដល់ថ្នាក់ទីបី ឬស្ថានភាពដែលនាំឱ្យមានភាពលំអៀងក្នុងការធ្វើអធិការកិច្ច ត្រូវដកខ្លួន និងរាយការណ៍ជូនប្រធានគណៈមេធាវី ដើម្បីធ្វើការផ្លាស់ប្តូរសមាសភាព។

ប្រសិនបើសមាសភាពក្រុមអធិការកិច្ចណាម្នាក់មានទំនាក់ទំនងញាតិរហូតដល់ថ្នាក់ទី៣ ហើយមិនបានស្នើសុំដកខ្លួន ឬរាយការណ៍តាមឋានានុក្រមទេ លទ្ធផលនៃការធ្វើអធិការកិច្ចនោះនឹងត្រូវចាត់ទុកជាមោឃៈ។ អធិការដែលមិនបានរាយការណ៍ពីករណីបែបនេះត្រូវទទួលរងទណ្ឌកម្មពីគណៈមេធាវី ដូចជាត្រូវដកឈ្មោះចេញពីក្រុមអធិការកិច្ច ឬ/និងស្តីបន្ទោសជាលាយលក្ខណ៍អក្សរ ឬដាក់វិន័យផ្សេងទៀតតាមក្រមសីលធម៌មេធាវី និងពុំអាចទទួលបាននូវប្រាក់ឧបត្ថម្ភសម្រាប់អធិការកិច្ចឡើយ។ ក្នុងករណីនេះ ប្រធានគណៈមេធាវីត្រូវចាត់តាំងក្រុមអធិការកិច្ចថ្មី ដើម្បីដំណើរនីតិវិធីអធិការកិច្ចសារជាថ្មីឡើងវិញលើសំណុំឯកសារពាក្យសុំរបស់បេក្ខជន។

### ប្រការ២០ .. រយៈពេលធ្វើអធិការកិច្ច

បន្ទាប់ពីទទួលការចាត់តាំងពីប្រធានគណៈមេធាវី ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងចប់សព្វគ្រប់ ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលការចាត់តាំង។ ប្រសិនបើមិនអាចធ្វើអធិការកិច្ចបានតាមអំឡុងពេលកំណត់នេះទេ ប្រធានក្រុមអធិការកិច្ចត្រូវរាយការណ៍ជូនប្រធានគណៈមេធាវីអំពីមូលហេតុនិងឧបសគ្គដែលបានកើតឡើងនៅពេលធ្វើអធិការកិច្ចនោះ។ ក្នុងករណីនេះ ប្រធានគណៈមេធាវីអាចសម្រេចពន្យារពេលដោយកំណត់អំឡុងពេលសមរម្យម្តងទៀត ឬចាត់តាំងក្រុមអធិការកិច្ចថ្មីដើម្បីបញ្ចប់កិច្ចការអធិការកិច្ចប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ។

ក្នុងករណីក្រុមអធិការកិច្ចបានទាក់ទងទៅបេក្ខជនតាមរយៈអាសយដ្ឋាន ឬលេខទូរស័ព្ទដែលបេក្ខជនបានសរសេរនៅក្នុងពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីរបស់សាមីខ្លួន ហើយនៅតែមិនអាចទំនាក់ទំនងបាន ក្រុមអធិការកិច្ចត្រូវរាយការណ៍ជូនប្រធានគណៈមេធាវី ។ ប្រធានគណៈមេធាវីមានឆន្ទានុសិទ្ធិក្នុងការលើកចោលពាក្យសុំចូលប្រកបវិជ្ជាជីវៈនោះដោយពុំបង្វិលប្រាក់ថ្លៃដាក់ពាក្យសុំជូនទៅបេក្ខជនវិញឡើយ ។

## ប្រការ២១ .. របាយការណ៍អធិការកិច្ច

ក្រោយពីបញ្ចប់បេសកកម្មរបស់ខ្លួន ក្រុមអធិការកិច្ចត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើអធិការកិច្ចរបស់ខ្លួនជូនមកប្រធានគណៈមេធាវី ក្នុងអំឡុងពេលដូចមានកំណត់ក្នុងប្រការ ២០ ខាងលើ ។

ទម្រង់របាយការណ៍អធិការកិច្ចត្រូវកំណត់ដោយគណៈមេធាវី សម្រាប់ប្រើជាផ្លូវការនៅក្នុងការបំពេញការងាររបស់ក្រុមអធិការកិច្ច ។

របាយការណ៍ត្រូវរៀបរាប់រាល់ព័ត៌មានដែលទទួលបានពីការធ្វើអធិការកិច្ច ដោយគួសបញ្ជាក់នូវព័ត៌មាននានាទាក់ទងនឹងលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវី តែមិនត្រូវធ្វើសេចក្ដីសន្និដ្ឋានថា បេក្ខជនមានលក្ខណៈសម្បត្តិ ឬមិនមានលក្ខណៈសម្បត្តិចូលប្រកបវិជ្ជាជីវៈមេធាវីនោះទេ ។

របាយការណ៍ត្រូវបញ្ជូនមកប្រធាននាយកដ្ឋានអធិការកិច្ចដើម្បីត្រួតពិនិត្យ និងវាយតម្លៃ មុននឹងបញ្ជូនមកប្រធានគណៈមេធាវីតាមចរន្តការឯកសារ ។

## ប្រការ២២ .. ការទទួលខុសត្រូវរបស់អធិការ

ក្រុមអធិការកិច្ចដែលបាន ឬមានបំណងបិតបាំងនូវកំហុសរបស់បេក្ខជននឹងត្រូវទទួលទណ្ឌកម្មពីប្រធានគណៈ-មេធាវី ដោយពុំទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌដែលចែងនៅក្នុងច្បាប់ ។

## ប្រការ២៣ .. ការពិនិត្យរបាយការណ៍

បន្ទាប់ពីទទួលបានរបាយការណ៍អធិការកិច្ចពីប្រធាននាយកដ្ឋានអធិការកិច្ច ប្រធានគណៈមេធាវីត្រូវត្រួតពិនិត្យអំពីទម្រង់ និងខ្លឹមសារនៃការធ្វើអធិការកិច្ច ។

ប្រសិនបើត្រឹមត្រូវតាមការកំណត់ ប្រធានគណៈមេធាវីត្រូវកំណត់ពេលសម្រាប់ធ្វើការប្រឡងសមត្ថភាពបេក្ខជនដូចបានកំណត់ក្នុងផ្នែកទី៤នៃជំពូកនេះ ។

ប្រសិនបើរបាយការណ៍នោះមិនត្រឹមត្រូវឬមានចំណុចខ្វះខាត ប្រធានគណៈមេធាវីនឹងបញ្ជូនសំណុំឯកសារនេះទៅក្រុមអធិការកិច្ចឱ្យធ្វើអធិការកិច្ចឡើងវិញ ក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយប្រធានគណៈមេធាវី ។

# ផ្នែកទី៤
# ការផ្ទៀងផ្ទាត់សមត្ថភាពបេក្ខជន

## ប្រការ២៤ .. ការប្រឡងសមត្ថភាពបេក្ខជន

បេក្ខជនត្រូវឆ្លងកាត់ការប្រឡងសមត្ថភាពលើវិញ្ញាសាសរសេរ និងសួរផ្ទាល់មាត់ នៅមុនពេលសំណុំឯកសាររបស់បេក្ខជនរូបនោះត្រូវបានបញ្ជូនទៅសុំយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ការប្រឡងលើវិញ្ញាសាសរសេរ ត្រូវរៀបចំដោយគណៈមេប្រយោគដែលដឹកនាំដោយប្រធានគណៈមេធាវី និងតំណាងអគ្គលេខាធិការដ្ឋាន១ (មួយ)រូប ជាសមាជិក។

## ប្រការ២៥ .. ការប្រឡងលើវិញ្ញាសាសរសេរ

គណៈមេប្រយោគត្រូវរៀបចំការប្រឡងសមត្ថភាពលើវិញ្ញាសាសរសេរក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលបញ្ចប់របាយការណ៍របស់ក្រុមអធិការកិច្ច។

មុខវិជ្ជានៃការប្រឡងវិញ្ញាសាសរសេររួមមាន ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវី។

បែបបទនៃការប្រឡងត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានគណៈមេធាវី។

## ប្រការ២៦ .. ការប្រឡងលើវិញ្ញាសាសួរផ្ទាល់មាត់

ប្រធានគណៈកម្មការត្រូវរៀបចំការប្រឡងសមត្ថភាពលើវិញ្ញាសាសួរផ្ទាល់មាត់ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការប្រឡងលើវិញ្ញាសាសរសេរត្រូវបានបញ្ចប់។

សមាសភាពរបស់គណៈកម្មការសម្ភាសន៍មានចំនួន ០៣រូបរួមមាន៖

-ប្រធានគណៈមេធាវី

-សមាជិកក្រុមប្រឹក្សាគណៈមេធាវី ០១រូប

-លេខាកត់ត្រា ០១រូប ដែលត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។

## ប្រការ២៧ .. ករណីលើកលែង

បេក្ខជនដែលអាចរួចផុតពីការប្រឡងលើវិញ្ញាសាសរសេរត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

-ឥស្សរៈជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ ដូចជា សមាជិកឬមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យច្បាប់

-ចៅក្រម ឬព្រះរាជអាជ្ញា ដែលបានបម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រច្បាប់

-សិស្សមេធាវីដែលបានបញ្ចប់វគ្គបណ្ដុះបណ្ដាល ហើយបានបម្រើការងារជាចៅក្រម ឬព្រះរាជអាជ្ញារយៈពេល ៥(ប្រាំ)ឆ្នាំ

-ជនជាតិខ្មែរដែលបានចុះបញ្ជី និងធ្វើជាមេធាវីពេញសិទ្ធិនៅបរទេស។

## ផ្នែកទី៥
## ការធ្វើសេចក្តីសម្រេចលើការស្នើសុំ

### ប្រការ២៨ .- ការស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា

ក្រោយពីឆ្លងកាត់ការប្រឡងសមត្ថភាពរួចរាល់ គណៈមេធាវីត្រូវបញ្ជូនសំណុំឯកសាររបស់បេក្ខជនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីត្រួតពិនិត្យលើលក្ខខណ្ឌដែលកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងស្នើសុំយោបល់ពីអគ្គព្រះរាជអាជ្ញា ។

សំណុំឯកសារដែលត្រូវបញ្ជូនទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដោយនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល រួមមាន ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ប្រវត្តិរូបសង្ខេប កិច្ចសន្យាផ្ទាល់ខ្លួន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សញ្ញាបត្រច្បាប់ លិខិតបញ្ជាក់ការងារ របាយការណ៍របស់អធិការកិច្ចគណៈមេធាវី និងលិខិតថ្កោលទោស ។

ក្នុងករណីបេក្ខជនជាជំនួយការមេធាវីឬទីប្រឹក្សាច្បាប់របស់មេធាវី ត្រូវភ្ជាប់ឯកសារបន្ថែមនូវលិខិតទទួលស្គាល់ជំនួយការមេធាវីឬទីប្រឹក្សាមេធាវី និងប័ណ្ណសម្គាល់ជំនួយការឬទីប្រឹក្សា ។

ក្នុងករណីបេក្ខជនមានលិខិតបញ្ជាក់ការងារចេញដោយវិស័យឯកជនត្រូវភ្ជាប់ឯកសារបន្ថែមនូវកិច្ចសន្យាការងារ ។

### ប្រការ២៩ .- នីតិវិធីនៃការសម្រេច

ការយល់ព្រមឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ក្នុងការសម្រេចអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យនិងសម្រេចតាមលំដាប់លំដោយមួយម្តងៗ លើលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវី រួមមាន សញ្ញាបត្រ បទពិសោធន៍ការងារ សមត្ថភាព និងការមានទោសពីមុន ។

ការបោះឆ្នោតដើម្បីអនុញ្ញាតឬមិនអនុញ្ញាតឱ្យបេក្ខជនចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវធ្វើជាសម្ងាត់ ។ ការសម្រេចគាំទ្របេក្ខជនត្រូវធ្វើឡើងតាមសំឡេងភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាននិងសំឡេងផ្ទេរសិទ្ធិ ដោយធៀបទៅនឹងលទ្ធផលសំឡេងយល់ព្រម មិនយល់ព្រម អនុប្បវាទឬមិនបានការ ។

ករណីសំឡេងអនុប្បវាទឬមិនបានការ ច្រើនជាងឬស្មើនឹងសំឡេងយល់ព្រមឬ/និងមិនយល់ព្រម ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី ។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ ។

ក្នុងករណីសំឡេងយល់ព្រមនិងមិនយល់ព្រមស្មើគ្នា ហើយច្រើនជាងសំឡេងអនុប្បវាទឬមិនបានការ ក្រុមប្រឹក្សាត្រូវបោះឆ្នោតសារជាថ្មី ។ នៅក្នុងការបោះឆ្នោតសារជាថ្មីនេះ ត្រូវយកតាមសំឡេងភាគច្រើនដោយធៀបតែរវាងសំឡេងយល់ព្រមនិងមិនយល់ព្រមប៉ុណ្ណោះ ។

ក្នុងករណីដែលក្រុមប្រឹក្សាគណៈមេធាវី សម្រេចមិនអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវៈមេធាវី ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញបេក្ខជនរូបនោះមកបញ្ចេញយោបល់នៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី ។ ការកោះអញ្ជើញនេះត្រូវធ្វើឡើងយ៉ាងតិច ១០(ដប់)ថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី ។ បន្ទាប់ពីស្តាប់យោបល់របស់

សាមីខ្លួនរួចហើយ សមាជិកក្រុមប្រឹក្សាគណៈមេធាវីអាចតាំងសំណួរបន្ថែមបាន។ ក្រោយការសួរសំណួរចប់សព្វគ្រប់ សាមីខ្លួនត្រូវចាកចេញពីបន្ទប់ប្រជុំ ហើយក្រុមប្រឹក្សាគណៈមេធាវីត្រូវពិភាក្សាគ្នានិងធ្វើការសម្រេចជាថ្មី។

## ប្រការ៣០ .. ការប្ដឹងតវ៉ាពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី

ក្នុងករណីក្រុមប្រឹក្សាគណៈមេធាវីសម្រេចមិនអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី គណៈមេធាវីត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះទៅសាមីខ្លួន ហើយសាមីខ្លួនមានសិទ្ធិប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងរយៈពេល ២(ពីរ)ខែចាប់ពីថ្ងៃទទួលដំណឹង។

## ប្រការ៣១ .. ការពិនិត្យនិងសម្រេចឡើងវិញ

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យលើសេចក្ដីសម្រេចរបស់ខ្លួននិងសម្រេចឡើងវិញ តាមសាលដីការបស់តុលាការ។

# ជំពូកទី៤
# ការធ្វើសច្ចាប្រណិធាន

## ប្រការ៣២ .. ការស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាន

ប្រធានគណៈមេធាវី ត្រូវបញ្ជូនឈ្មោះបេក្ខជនដែលត្រូវបានក្រុមប្រឹក្សាគណៈមេធាវីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ដោយភ្ជាប់ជាមួយនូវសេចក្ដីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី ដោយមានការបញ្ជាក់ពីនាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលគណៈមេធាវីថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ការស្នើសុំកាលបរិច្ឆេទធ្វើសច្ចាប្រណិធាននេះត្រូវធ្វើឡើងយ៉ាងយូរបំផុត ៣០(សាមសិប)ថ្ងៃ ដោយគិតពីថ្ងៃចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី។

បេក្ខជនត្រូវចូលរួមធ្វើសច្ចាប្រណិធានតាមកាលបរិច្ឆេទកំណត់។

## ប្រការ៣៣ .. តំណាងគណៈមេធាវីក្នុងកិច្ចសច្ចាប្រណិធាន

បន្ទាប់ពីបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃការធ្វើសច្ចាប្រណិធាន ប្រធានគណៈមេធាវីឬតំណាងដែលចាត់តាំងដោយប្រធានគណៈមេធាវី ត្រូវចូលរួមក្នុងកិច្ចសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ។

# ជំពូកទី៥
# ការធ្វើកម្មសិក្សា និងការសុំពន្យារកម្មសិក្សា

## ប្រការ៣៤ .. ការដាក់ពាក្យសុំធ្វើកម្មសិក្សា

បេក្ខជនត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សាក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ជាមួយគ្រូកម្មសិក្សាណាម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានទីតាំងប្រកបវិជ្ជាជីវៈមេធាវីច្បាស់លាស់ និងងាយស្រួលទំនាក់ទំនងទៅវិញទៅមករវាងគណៈមេធាវីនិងគ្រូកម្មសិក្សា។

ទម្រង់នៃពាក្យសុំធ្វើកម្មសិក្សាត្រូវកំណត់ដោយគណៈមេធាវី ។ ពាក្យសុំនេះត្រូវមានសេចក្ដីបញ្ជាក់យល់ព្រមរបស់គ្រូកម្មសិក្សា ដោយមានចុះហត្ថលេខា ត្រាមេធាវី និងឈ្មោះរបស់គ្រូកម្មសិក្សា ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុសច្ចាប្រណិធាន ។ ទម្រង់នៃពាក្យសុំធ្វើកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ១ នៃសេចក្ដីសម្រេចនេះ ។

កម្មសិក្សាការីត្រូវបង្ហាញជូនគណៈមេធាវីឱ្យបានច្បាស់លាស់ថា ខ្លួនពុំមានវិសមិតភាពក្នុងការប្រកបវិជ្ជាជីវៈមេធាវីនោះឡើយ ។ ក្នុងករណីមានវិសមិតភាព កម្មសិក្សាការីត្រូវសុំព្យួរឬលាឈប់ពីការងារ ដែលមានវិសមិតភាពនោះសិន ។ ឯកសារដែលបញ្ជាក់ពីការព្យួរឬលាឈប់ពីការងារនេះត្រូវភ្ជាប់មកជាមួយពាក្យសុំធ្វើកម្មសិក្សា ។

## ប្រការ៣៥ ._ ការដាក់ពាក្យសុំព្យួរកម្មសិក្សា

ដោយមានមូលហេតុសមស្រប បេក្ខជនអាចដាក់ពាក្យសុំព្យួរកម្មសិក្សាក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ សម្រាប់រយៈពេលមិនលើសពី២(ពីរ)ឆ្នាំម្ដង ។ បេក្ខជនអាចដាក់ពាក្យសុំបន្តការព្យួរកម្មសិក្សាជាបន្តបន្ទាប់ទៀតបាន ដោយមានបញ្ជាក់នូវមូលហេតុសមស្រប ។ ទម្រង់នៃពាក្យសុំព្យួរកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ២ នៃសេចក្ដីសម្រេចនេះ ។

មូលហេតុសមស្របមានជាអាទិ៍៖

១-បេក្ខជនសាមីបំពេញការងារមានវិសមិតភាពជាមួយនឹងវិជ្ជាជីវៈមេធាវី ឬ

២-បេក្ខជនសាមីកំពុងបំពេញការងារ ឬសិក្សា ឬស្រាវជ្រាវនៅបរទេស ឬ

៣-បេក្ខជនសាមីកំពុងសម្រាកព្យាបាលជម្ងឺ នៅក្នុងស្រុក ឬបរទេស ឬ

៤-បេក្ខជនសាមីមានបញ្ជាក់នូវមូលហេតុសមស្របផ្សេងទៀត ។

ក្នុងរយៈពេលព្យួរកម្មសិក្សា បេក្ខជនមានកាតព្វកិច្ចបង់ប្រាក់ស្មើនឹងពាក់កណ្ដាលនៃប្រាក់ភាគទានរបស់មេធាវីពេញសិទ្ធិ ។

ការអនុញ្ញាតឱ្យព្យួរកម្មសិក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

## ប្រការ៣៦ ._ ការខកខានក្នុងការដាក់ពាក្យសុំធ្វើកម្មសិក្សា ឬដាក់ពាក្យសុំព្យួរកម្មសិក្សា

ក្នុងករណីបេក្ខជនមិនបានដាក់ពាក្យសុំធ្វើកម្មសិក្សា ឬដាក់ពាក្យសុំព្យួរកម្មសិក្សាក្នុងរយៈពេលកំណត់ក្នុងប្រការ ៣៤ និងប្រការ ៣៥ ខាងលើ គណៈមេធាវីចាត់ទុកថា បេក្ខជនបោះបង់ចោលការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីសម្រេចលុបចោលការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី ។

## ប្រការ៣៧ ._ រយៈពេលនៃការធ្វើកម្មសិក្សា

រយៈពេលនៃការធ្វើកម្មសិក្សាជាមួយគ្រូកម្មសិក្សាគឺមានរយៈពេល ១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យធ្វើកម្មសិក្សា ។ សាមីខ្លួនអាចដាក់ពាក្យសុំពន្យាពេលការដាក់របាយការណ៍បញ្ចប់កម្មសិក្សាដោយបញ្ជាក់មូលហេតុសមស្របជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមិនលើសពី ២ (ពីរ)ខែ គិតចាប់ពីថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ។ ក្នុងករណីខកខានក្នុងការដាក់ពាក្យសុំពន្យារពេលដាក់របាយការណ៍បញ្ចប់កម្មសិក្សា គណៈមេធាវីចាត់ទុកថា បេក្ខជនបោះបង់ចោលការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយក្រុមប្រឹក្សាគណៈមេធាវីសម្រេចលុបឈ្មោះចេញពីបញ្ជីមេធាវីកម្មសិក្សា ។ ទម្រង់នៃពាក្យសុំពន្យាពេលការដាក់របាយការណ៍បញ្ចប់កម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ៣ នៃសេចក្ដីសម្រេចនេះ ។

ការអនុញ្ញាតឱ្យពន្យាពេលការដាក់របាយការណ៍បញ្ចប់កម្មសិក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

ក្នុងរយៈពេលនៃការពន្យារការដាក់របាយការណ៍បញ្ចប់កម្មសិក្សា បេក្ខជនត្រូវបង់ប្រាក់ ស្មើនឹងពាក់កណ្តាលនៃប្រាក់ភាគទានមេធាវីពេញសិទ្ធិ។

## ប្រការ៣៨ .. ការជ្រើសរើសគ្រូកម្មសិក្សា

គ្រូកម្មសិក្សាត្រូវជ្រើសរើសដោយស្ម័គ្រចិត្តនិងតាមការព្រមព្រៀងរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការី ដោយត្រូវមានកិច្ចសន្យាសហការរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការី។

ទម្រង់កិច្ចសន្យាសហការរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការីត្រូវកំណត់ដោយគណៈមេធាវី និងអាចកំណត់បន្ថែមតាមការព្រមព្រៀង។ ទម្រង់គំរូនៃកិច្ចសន្យាសហការរវាងគ្រូកម្មសិក្សា និងកម្មសិក្សាការីមានភ្ជាប់ជាឧបសម្ព័ន្ធ៤នៃសេចក្តីសម្រេចនេះ។

គ្រូកម្មសិក្សាត្រូវមានលក្ខណៈសម្បត្តិតាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើគ្រូកម្មសិក្សាមិនមានលក្ខណៈសម្បត្តិដូចកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាគណៈមេធាវីនឹងមិនសម្រេចអនុញ្ញាតឱ្យកម្មសិក្សាការីធ្វើកម្មសិក្សាជាមួយគ្រូកម្មសិក្សានោះទេ។ ករណីនេះ កម្មសិក្សាការីត្រូវជ្រើសរើសគ្រូថ្មីក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រោយពេលទទួលដំណឹង។

កម្មសិក្សាការីអាចផ្លាស់ប្តូរគ្រូកម្មសិក្សាបានលុះត្រាតែគោរពតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

- មានមូលហេតុគ្រប់គ្រាន់ដែលបញ្ជាក់ថាគ្រូកម្មសិក្សាពុំអាចបន្តការដឹកនាំតទៅទៀតបាន ដូចជា ទទួលមរណៈភាព ត្រូវទណ្ឌកម្មវិន័យផ្អាកការប្រកបវិជ្ជាជីវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬមូលហេតុប្រធានសក្តិជាដើម
- ករណីចង់ប្តូរគ្រូកម្មសិក្សាក្រៅពីលក្ខខណ្ឌខាងលើ អាចធ្វើទៅបានលុះត្រាតែកម្មសិក្សាការីធ្វើកម្មសិក្សាបានរយៈពេលពេញ ០៦(ប្រាំមួយ)ខែរួចហើយ។

ទម្រង់នៃពាក្យសុំប្តូរគ្រូកម្មសិក្សា មានភ្ជាប់ជាឧបសម្ព័ន្ធ៥នៃសេចក្តីសម្រេចនេះ។

## ប្រការ៣៩ .. ភារកិច្ចរបស់កម្មសិក្សាការី

កម្មសិក្សាការីត្រូវគោរពការណែនាំរបស់គ្រូកម្មសិក្សា និងត្រូវបំពេញការងាររបស់ខ្លួនឱ្យស្របតាមច្បាប់ ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងគណៈមេធាវី និងសេចក្តីសម្រេចនានារបស់គណៈមេធាវី។

កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គសុក្រិត្យការវិជ្ជាជីវៈមេធាវី និងការបណ្តុះបណ្តាលនានាតាមការកំណត់របស់គណៈមេធាវី។

ក្នុងរយៈពេលកម្មសិក្សា កម្មសិក្សាការីមានកាតព្វកិច្ចការពារក្តី ឬតំណាងដោយអាណត្តិជូនជនក្រីក្រដោយឥតយកកម្រៃ និងផ្តល់ការពិគ្រោះយោបល់ឥតយកកម្រៃជូនជនក្រីក្រ តាមការចាត់តាំងរបស់គណៈមេធាវី។ ការការពារក្តី ការតំណាងដោយអាណត្តិ និងការពិគ្រោះយោបល់នេះ ត្រូវបញ្ចូលក្នុងរបាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី។

ទណ្ឌកម្មដែលក្រុមប្រឹក្សាគណៈមេធាវីអាចដាក់ចំពោះកម្មសិក្សាការី គឺឱ្យធ្វើកម្មសិក្សាបន្ថែមក្នុងរយៈពេលមិនលើសពី១(មួយ)ឆ្នាំ ដោយបង់ប្រាក់ដូចបានកំណត់ក្នុងប្រការ៣៧(រយៈពេលនៃការធ្វើកម្មសិក្សា)នៃសេចក្តីសម្រេចនេះ ឬលុបឈ្មោះពីបញ្ជីមេធាវីកម្មសិក្សា។

## ប្រការ៤០ .. ភារកិច្ចរបស់គ្រូកម្មសិក្សា

គ្រូកម្មសិក្សាត្រូវទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់កម្មសិក្សាការី ចំពោះការប្រកបវិជ្ជាជីវៈមេធាវី និងការធ្វើរបាយការណ៍បញ្ចប់កម្មសិក្សា។

បើកម្មសិក្សាការីមានកំហុសក្នុងការប្រកបវិជ្ជាជីវៈមេធាវីក្នុងអំឡុងពេលកម្មសិក្សា ដូចជា ការបំពេញឯកសារពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី ការតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យតតិយុត្ត ឬការផ្តល់យោបល់ផ្នែកច្បាប់ ជាអាទិ៍ ត្រូវចាត់ទុកជាកំហុសរួមរបស់គ្រូកម្មសិក្សានិងកម្មសិក្សាការី។

ទណ្ឌកម្មដែលក្រុមប្រឹក្សាគណៈមេធាវីអាចដាក់ចំពោះគ្រូកម្មសិក្សាមានជាអាទិ៍ ការដកសិទ្ធិជាគ្រូកម្មសិក្សាមិនលើសពី ០២(ពីរ)ឆ្នាំ ឬការប្តូរគ្រូកម្មសិក្សា ឬទណ្ឌកម្មដទៃទៀត អាស្រ័យលើទំហំនៃកំហុសជាក់ស្តែងរបស់គ្រូកម្មសិក្សា។

# ជំពូកទី៦
# ការលើកលែងការធ្វើកម្មសិក្សា

## ប្រការ៤១ .. ការដាក់ពាក្យសុំ

បេក្ខជនដែលមានបំណងសុំលើកលែងការធ្វើកម្មសិក្សា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងប្រការ៤២ (លក្ខណៈសម្បត្តិ)ខាងក្រោម ហើយអាចដាក់ពាក្យសុំដោយភ្ជាប់ជាមួយនឹងមូលហេតុជាលាយលក្ខណ៍អក្សរ និងភស្តុតាងគាំទ្រនូវមូលហេតុទាំងនោះមកគណៈមេធាវី។ សំណើនេះនឹងដាក់ជូនក្រុមប្រឹក្សាសម្រេច ក្នុងរយៈពេលសមរម្យ។

ទម្រង់នៃពាក្យសុំលើកលែងកម្មសិក្សាមានភ្ជាប់ជាឧបសម្ព័ន្ធ៦នៃសេចក្តីសម្រេចនេះ។

## ប្រការ៤២ .. លក្ខណៈសម្បត្តិ

បេក្ខជនដែលមានលក្ខណៈសម្បត្តិដូចបានកំណត់ខាងក្រោមនេះអាចពិចារណាឱ្យរួចផុតពីកម្មសិក្សា៖

- ឥស្សរៈជនជាន់ខ្ពស់ដែលបានបម្រើការងារយ៉ាងតិច ១០(ដប់)ឆ្នាំ ហើយមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងវិស័យច្បាប់ ដូចជា សមាជិកឬមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យច្បាប់
- ចៅក្រមឬព្រះរាជអាជ្ញា ដែលបានបម្រើការងារយ៉ាងតិច ១០(ដប់)ឆ្នាំ និងមានបរិញ្ញាបត្រច្បាប់
- អ្នកដែលមានវិញ្ញាបនបត្រសម្ងទាខាងវិជ្ជាជីវៈមេធាវី ហើយបានបម្រើការងារជាចៅក្រម ឬព្រះរាជអាជ្ញារយៈពេល ០៧(ប្រាំពីរ)ឆ្នាំ
- ជនជាតិខ្មែរដែលបានចុះបញ្ជីនិងធ្វើជាមេធាវីពេញសិទ្ធិនៅបរទេស។

## ប្រការ៤៣ .. ភារកិច្ចរបស់បេក្ខជនស្នើសុំរួចផុតកម្មសិក្សា

បេក្ខជនដែលស្នើសុំរួចផុតកម្មសិក្សាត្រូវគោរពកាតព្វកិច្ចនានាដែលបានកំណត់ដោយបទប្បញ្ញត្តិទាក់ទងនឹងវិធានវិជ្ជាជីវៈមេធាវីនិងសេចក្តីសម្រេចនានារបស់គណៈមេធាវី។

បេក្ខជនដែលស្នើសុំរួចផុតកម្មសិក្សាត្រូវចូលរួមក្នុងវគ្គសុក្រិត្យការវិជ្ជាជីវៈមេធាវីនិងការបណ្តុះបណ្តាលនានាដែលតម្រូវដោយគណៈមេធាវីទៅតាមការកំណត់និងចំនួនម៉ោងនៃការសិក្សារបស់គណៈមេធាវី លើកលែងតែបេក្ខជន

នោះបានបញ្ចប់ការសិក្សានិងទទួលវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ ប្រសិនបើបេក្ខជននោះមិនបានចូលរួមនិងបញ្ចប់វគ្គសុក្រឹតការដែលតម្រូវដោយគណៈមេធាវីទេនោះ បេក្ខជននោះមិនអាចប្រកបវិជ្ជាជីវៈមេធាវីបានឡើយ។

## ជំពូកទី៧
## ការបញ្ចប់ការធ្វើកម្មសិក្សា

### ប្រការ៤៤ .. ការធ្វើរបាយការណ៍

កម្មសិក្សាការីដែលបានបំពេញកម្មសិក្សារបស់ខ្លួនជាមួយគ្រូកម្មសិក្សានៅក្នុងរយៈពេលដែលបានកំណត់ដោយគណៈមេធាវីរួចហើយ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពនៃការបំពេញវិជ្ជាជីវៈមេធាវីរបស់ខ្លួនមកគណៈមេធាវី ដើម្បីឱ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យនិងសម្រេច អំពីការអនុញ្ញាតឬមិនអនុញ្ញាតឱ្យចុះបញ្ជីគណៈមេធាវី។

របាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី ត្រូវមានភ្ជាប់ជាមួយនឹងលិខិតដែលបញ្ជាក់អំពីយោបល់របស់គ្រូកម្មសិក្សានិងភស្តុតាងនានាដែលបញ្ជាក់អំពីការបំពេញការងារវិជ្ជាជីវៈមេធាវី សម្រាប់គាំទ្រសកម្មភាពដែលបានបរិយាយក្នុងរបាយការណ៍ និងជាមូលដ្ឋាននៃការបញ្ជាក់អំពីសមត្ថភាពនៃការប្រកបវិជ្ជាជីវៈមេធាវី។

### ប្រការ៤៥ .. ទម្រង់និងខ្លឹមសារនៃរបាយការណ៍

កម្មសិក្សាការីត្រូវធ្វើរបាយការណ៍តាមទម្រង់ដែលកំណត់ដោយគណៈមេធាវីដូចខាងក្រោម ៖

**១. ទម្រង់**

របាយការណ៍ត្រូវមាន៖

- កំរាស់យ៉ាងច្រើនចំនួន ២០(ម្ភៃ)ទំព័រ ដោយមានរឹមខាងលើទំហំ ២០ (ម្ភៃ)មីលីម៉ែត្រ និងខាងក្រោមទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ។ ចំពោះរឹមខាងស្តាំមានទំហំ ១៥ (ដប់ប្រាំ)មីលីម៉ែត្រ និងខាងឆ្វេងទំហំ ២៥ (ម្ភៃប្រាំ)មីលីម៉ែត្រ។
- សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

**២. ចំនួនរឿងក្តី**

ក្នុងរយៈពេលកម្មសិក្សា កម្មសិក្សាការីត្រូវបំពេញកិច្ចការពារក្តីនិងតំណាងដោយអាណត្តិដូចខាងក្រោម៖

- រឿងក្តីព្រហ្មទណ្ឌចំនួន ០៣ (បី) យ៉ាងតិច
- រឿងក្តីរដ្ឋប្បវេណីចំនួន ០៣ (បី) យ៉ាងតិច
- ការពិគ្រោះយោបល់ច្បាប់ចំនួន ០៥ (ប្រាំ) ករណីយ៉ាងតិច។

**៣. ខ្លឹមសារ**

- ត្រូវសង្ខេបកិច្ចការដែលខ្លួនបានបំពេញក្នុងរយៈពេលធ្វើកម្មសិក្សា
- ត្រូវលើកយករឿងក្តីព្រហ្មទណ្ឌ ០១ (មួយ)ករណី ដែលការពារសិទ្ធិឱ្យជនជាប់ចោទ នៅដំណាក់កាលជំនុំជម្រះ និងរឿងក្តីរដ្ឋប្បវេណី ០១ (មួយ)ករណី ដែលខ្លួនបានបញ្ចប់ការការពារនិងតំណាងដោយអាណត្តិមកបង្ហាញ
- ត្រូវបង្ហាញសមត្ថភាពក្នុងការការពារក្តីក្នុងរឿងនោះ ដោយផ្តល់យុទ្ធសាស្ត្រសម្រាប់ការការពាររឿងក្តីរួមមានអង្គហេតុសង្ខេប ចំណុចខ្សោយ ចំណុចខ្លាំង ទ្រឹស្តីការពារ សេចក្តីសន្និដ្ឋានឬសេចក្តីថ្លែងការណ៍ និងលទ្ធផលនៃការការពារឬតំណាងដោយអាណត្តិ

- ត្រូវមានឯកសារយោងភ្ជាប់មកជាមួយ ចំពោះរឿងក្តីទាំងពីរដែលបានលើកមកបង្ហាញនៅក្នុងរបាយការណ៍។ ចំពោះរឿងក្តីផ្សេងទៀតត្រូវដាក់ក្នុងលេខយោងនៅចុងទំព័រ ។
- កម្មសិក្សាការីត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវនៅរបាយការណ៍បញ្ចប់កម្មសិក្សា ។ ក្នុងករណីកម្មសិក្សាការីផ្តល់ព័ត៌មានមិនពិតត្រូវទទួលទណ្ឌកម្មវិន័យ ។

**ប្រការ៤៦ .. ការដាក់និងការពិនិត្យលើរបាយការណ៍**

កម្មសិក្សាការីត្រូវដាក់របាយការណ៍បញ្ចប់កម្មសិក្សាចំនួន ៥ (ប្រាំ)ច្បាប់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ជាទម្រង់អេឡិចត្រូនិក (PDF) ។

របាយការណ៍នោះត្រូវបញ្ជូនមកប្រធានគណៈមេធាវីដើម្បីចាត់តាំងគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងវាយតម្លៃទៅលើរបាយការណ៍នោះ ។

សមាសភាពគណៈកម្មការចំពោះកិច្ចនេះ គឺជាសមាជិកក្រុមប្រឹក្សា ដែលត្រូវពិនិត្យទៅលើយោបល់របស់គ្រូកម្មសិក្សា ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ដូចមានកំណត់ក្នុងប្រការ៤៥ ខាងលើ ។

**ប្រការ៤៧ .. ការសម្រេចលើការបញ្ចប់កម្មសិក្សា និងការចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី**

ក្រុមប្រឹក្សាគណៈមេធាវីនឹងពិនិត្យទៅលើរបាយការណ៍របស់កម្មសិក្សាការី យោបល់របស់គណៈកម្មការចំពោះកិច្ច និងវាយតម្លៃលើរបាយការណ៍ យោបល់គ្រូកម្មសិក្សា និងស្ថានភាពជាក់ស្តែងនៃការបំពេញការងារវិជ្ជាជីវៈមេធាវីរបស់កម្មសិក្សាការី ។

ប្រសិនបើរបាយការណ៍មានលក្ខណៈត្រឹមត្រូវតាមការកំណត់នៃលក្ខខណ្ឌ ទម្រង់ និងខ្លឹមសារ ដូចមានកំណត់ក្នុងប្រការ៤៥ នៃសេចក្តីសម្រេចនេះ ក្រុមប្រឹក្សាគណៈមេធាវីត្រូវសម្រេចចុះឈ្មោះរបស់កម្មសិក្សាការីរូបនោះក្នុងបញ្ជីគណៈមេធាវី ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**ប្រការ៤៨ .. ការលើកលែងអនុវត្ត**

ផ្នែកទី ៤ ជំពូកទី ៣ នៃសេចក្តីសម្រេចនេះមិនអនុវត្តចំពោះបេក្ខជនដែលទទួលបានយោបល់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញរួចហើយគិតត្រឹមកាលបរិច្ឆេទនៃសេចក្តីសម្រេចនេះ ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ៤៩ .. និរាករណ៍**

សេចក្តីសម្រេចលេខ០១១/សសគម/១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីការដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ សេចក្តីសម្រេចលេខ៧១១/សសគម/១៧ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងសេចក្តីសម្រេចលេខ០៩៦/សសគម/១៩ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលប្រការ២៣ និងប្រការ២៤ នៃសេចក្តីសម្រេចលេខ៧១១/សសគម/១៧ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី

នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥០ .. ការចូលជាធរមាន**

សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខារបស់ប្រធានគណៈមេធាវីតទៅ។

ថ្ងៃ ចន្ទ ៤ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**ប្រធាន**

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី លី-ច័ន្ទតុលា

***ចម្លងជូនៈ***

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

-ក្រុមប្រឹក្សាគណៈមេធាវី

“ដើម្បីជ្រាប”

-ឯកសារ-កាលប្បវត្តិ